ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ១២៨/២០ គ.ជ.ប.ជ.

# របាយការណ៍ខែមិថុនា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែកក្កដា ឆ្នាំ២០២០

## I. ស្ថានភាពទូទៅ

ក្រសួងស្ថាប័ន និងរាជធានី ខេត្ត បានប្តូរទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិ ខូវីដ-១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឲ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការ ដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេស អ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួន ច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺខូវីដ-១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជម្ងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឲ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស ។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូបានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឲ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិខូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្សក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

ខ.១.១. ការផ្សព្វផ្សាយជាសាធារណៈ

| ល.រ | ផ្សព្វផ្សាយតាមរយៈ | ចំនួនលើក | ចំនួនអ្នកចូលរួម |
|---|---|---|---|
| ១ | វេទិកាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព | ៦.៣១៨ លើក | ២៤២.៣៧១ នាក់ |
| ២ | អង្គការដៃគូនានា | ៨៩ លើក | ៩.៩៦០ នាក់ |
| សរុប | | ៦.៤០៧ លើក | ២៥២.៣៣១ នាក់ |

ខ.១.២. វេទិកាសាធារណៈ និងភូមិ ឃុំសុវត្ថិភាព

នៅក្នុងខែមិថុនា ឆ្នាំ២០២០នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន ៦.៣១៨លើក មានអ្នកចូលរួមសរុបចំនួន ២៤២.៣៧១នាក់ (ធៀបនឹងខែមេសា មានចំនួន ២៥៣.១៦៦នាក់ គឺមាន

ការថយចុះចំនួន ១០.៧៩៥នាក់ ស្មើនឹង៤,៤៥% ក្នុងនោះស្ត្រីចំនួន ១៣៧.០០៨នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៤៣២ | ១៤.៧១៧ | ៨.៨៤២ | | | |
| | សរុប ក្រសួង ស្ថាប័ន | ៤៣២ លើក | ១៤.៧១៧ នាក់ | ៨.៨៤២ នាក់ | | | |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៩៨៥ | ៥៦.៧៣០ | ៣៥.៩២៨ | | | |
| ៣ | ខេត្តបាត់ដំបង | ១.៥៩៥ | ៥៦.២០១ | ២៨.៨០៦ | ១.០៧៨ | ២៧.៦៧៦ | ១៤.៨៩០ |
| ៤ | ខេត្តពោធិ៍សាត់ | ២៣៨ | ២៣.៤០៧ | ១២.០៤៣ | ១៥១ | ៥.៤១០ | ២.៥៧០ |
| ៥ | ខេត្តសៀមរាប | ៣៤៧ | ១០.៩៦៩ | ៦.៨០៨ | ១១១ | ២.២៤២ | ១.៣០៥ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៣៥៤ | ១១.០៥៩ | ៥.៩៧៦ | ៣៥៤ | ១១.០៥៩ | ៥.៩៧៦ |
| ៧ | ខេត្តកំពង់ចាម | | | | | | |
| ៨ | ខេត្តព្រះសីហនុ | ១៤ | ៥០២ | ៣.២៩១ | ៥០ | ១.៥៤៤ | ៨២០ |
| ៩ | ខេត្តព្រះវិហារ | | | | | | |
| ១០ | ខេត្តស្វាយរៀង | ១៤១ | ៤.០៥៥ | ២.១០៩ | ៣៤០ | ១០.៥៤៩ | ៥.៦៣៤ |
| ១១ | ខេត្តប៉ៃលិន | ៩០ | ១.៩១៩ | ៩៨៤ | ៦០ | ១.៤៦២ | ៧៥០ |
| ១២ | ខេត្តកោះកុង | | | | | | |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | ២១៧ | ៧.៧៩០ | ៣.២២៧ | ៧៣ | ២.៦០៧ | ១.០៥៥ |
| ១៦ | ខេត្តក្រចេះ | ៤០ | ១.៩០៦ | ១.០៦៥ | | | |
| ១៧ | ខេត្តកែប | | | | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ១ | ១.៦០៧ | ៩០២ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ១ | ១៩ | ៣ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ៤.០២៣ លើក | ១៧៦.១៦៤ នាក់ | ១០១.១៤២ នាក់ | ១.៨៦៣ លើក | ៥១.៤៩០ នាក់ | ២៧.០២៤ នាក់ |
| | សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន ៦.៣១៨ លើក | | អ្នកចូលរួមសរុប ២៤២.៣៧១ នាក់ | | ស្ត្រីចំនួន ១៣៧.០០៨ នាក់ | |

## ខ.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

▪ អង្គការដៃគូ

*តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ របស់អង្គការដៃគូនានា តាមបណ្ដាលរាជធានី-ខេត្ត*

| រាជធានី-ខេត្ត | *សកម្មភាព* | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
|---|---|---|---|---|
| ខេត្តសៀមរាប<br>អង្គការបន្ទាយស្រី<br>អង្គការវីវើល/ជីវីស៊ី<br>អង្គការមូលនិធិអេ២១<br>ដៃនដីមនុស្ស ហូឡង់ដ៍ | - សហការជាមួយអាជ្ញាធរមូលដ្ឋាន ផ្សព្វផ្សាយស្ដីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព សិទ្ធិការងាររបស់ពលករចំណាកស្រុក និងច្បាប់ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់អាជ្ញាធរស្រុក ប្រជាពលរដ្ឋ និងសិស្សានុសិស្ស នៅស្រុកអង្គរជុំ ស្រុកជីក្រែង និងស្រុកពួក។ | ៨៩ | ៩.៩៦០ | ៤.០៥៧ |
| សរុប | | ៨៩ លើក | ៩.៩៦០នាក់ | ៤.០៥៧ នាក់ |

## ខ.១.៤. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិកត្រូនិក

- ខេត្តសៀមរាប៖ មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុ FM ជាតិនគរភ្នំ ១០៣MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប អំពីអំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ពិសេសការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិល និងការផ្សព្វផ្សាយអំពីស្ពតអប់រំ ស្ដីពីគ្រឿងញៀន ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងពាក់ព័ន្ធការជួញដូរមនុស្ស សរុបចំនួន ៤៨លើក (ផ្សាយផ្ទាល់ ១២លើក និងចាក់ផ្សាយឡើងវិញ ៣៦លើក)។
- ខេត្តតាកែវ៖ មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយច្បាប់នានាពាក់ព័ន្ធ នឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុគោកធ្លក សរុបចំនួន ៣០អត្ថបទ និង ៣៨លើក។
- ខេត្តមណ្ឌលគិរី៖ មន្ទីរធម្មការ និងសាសនាខេត្ត បានផ្សព្វផ្សាយតាមរយៈវិទ្យុជាតិ FM 97MHz ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងកម្មវិធី "ព្រះពុទ្ធសាសនា ផ្សាភ្ជាប់សង្គម" ចំនួន ២០លើក។

## ខ.១.៥. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

- **ថ្នាក់ក្រោមជាតិ**

- ខេត្តបាត់ដំបង៖ តំណាងមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីវិទ្យុខេមរា FM 91MHz របស់គម្រោង "**នៅក៏មានសុវត្ថិភាព ចំណាកស្រុកក៏មានសុវត្ថិភាព**" នៃអង្គការសាម៉ារីតាន់ភឺស ០១លើក និងចូលរួមជាវាគ្មិនកម្មវិធីសន្ទនាមតិវិទ្យុជាតិកម្ពុជាខេត្តបាត់ដំបង FM 92.70MHzក្រោមប្រធានបទ "**ទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ**" ០១លើក។
- ខេត្តសៀមរាប៖ មន្ទីរការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិននៅប៉ុស្តិ៍វិទ្យុជាតិនគរភ្នំ ស្ដីពី"ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការអនុវត្តច្បាប់ស្ដីពីការងាររបស់កម្មករនិយោជិត និងនិយោជក ចំនួន ០១លើក។
- ខេត្តក្រចេះ៖ បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីវិទ្យុ និងឡាយតាមហ្វេសបុក របស់វិទ្យុសម្លេងស្ត្រីខេត្តក្រចេះ ស្ដីពីការរំលោភបំពានលើស្ត្រី និងកុមារ បានចំនួន ០១លើក។
- ខេត្តប៉ៃលិន៖ មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាមគ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡូ កាស៊ីណូ ឡឥដ្ឋ និងអាហារដ្ឋានចំនួន ៨០កន្លែង។

## ខ.២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានប្រមូលទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុក ត្រឡប់មកពីក្រៅប្រទេសវិញទាំងស្របច្បាប់ និងមិនស្របច្បាប់សរុបចំនួន ៨៧.៧៧០នាក់/ ៨១.៧៧០នាក់ (ស្រី ៣៧.៦៦០នាក់) អនីតិជន១.៨៦២នាក់។

- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរនគរបាលការពារ ព្រំដែនគោកវរសេនាតូចលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែន ភូមិសាស្ត្ររបស់ខ្លួនបានចំនួន ៤០លើក ហើយបានប្រទះឃើញពលករឆ្លងដែនខុសច្បាប់ចំនួន ៤៦១នាក់ (ស្រី ១៩៦នាក់ អនីតិជន ៣១នាក់) បានធ្វើការអប់រំ និងឲ្យត្រឡប់ទៅផ្ទះវិញ។

### ខ.២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង តាកែវ រតនគិរី ក្រចេះ និងខេត្តព្រះវិហារ បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ៣០លើក។
- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ក្រចេះ និងខេត្តមណ្ឌលគិរី បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ប្រឆាំងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ ម៉ាស្សា ចំនួន ២៦៦គោលដៅ មនុស្សចូលរួម ២៤.៩៥១នាក់ ស្រី១២.៧១៥នាក់។

### ខ.២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) នៃច្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃទទួលបន្ទុកការងារ អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន ៤០គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលរៀបការរួចហើយទៅរស់នៅសាធារណៈរដ្ឋកូរ៉េ និងប្រទេសចិន ដោយបានទំនាក់ទំនងតាមទូរស័ព្ទផ្ទាល់របស់សាមីខ្លួនបានចំនួន ០៣នាក់(រស់នៅជាមួយគ្រួសារសុខសប្បាយជាធម្មតា)។

## ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ខេត្តក្រចេះ៖** មន្ទីរ ស.អ.យ បានចុះធ្វើអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារនៅមណ្ឌលអង្គការដំណឹងល្អទាំង៤ និងភូមិកុមារកម្ពុជា SOS មានចំនួន ចំនួន ២មណ្ឌល។
- **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញដែលបានដាក់ចំនួន ១.២២៧នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍)។
- **ខេត្តពោធិ៍សាត់៖** មណ្ឌលកុមារកំព្រារដ្ឋចំនួន០១ មណ្ឌលកុមារកំព្រាអង្គការចំនួន១២ និងមានកុមាររស់នៅសរុប ១៨៧នាក់ ស្រី៨៧នាក់។

## ខ.៤. ការកាត់បន្ថយភាពរងគ្រោះ តាមរយៈការផ្តល់ប័ណ្ណព្រំដែនដល់មុខសញ្ញារងគ្រោះ

- រដ្ឋបាលខេត្តចំនួន០៣ គឺខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន ២៤២ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មាន៖

- ខេត្តបាត់ដំបង ចំនួន ២០៣ ប័ណ្ណ
- ខេត្តប៉ៃលិន ចំនួន ៣៩ ប័ណ្ណ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្តៈ រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កណ្តាល ក្រចេះ មណ្ឌលគិរី ព្រៃវែង ពោធិ៍សាត់ រតនគិរី សៀមរាប ព្រះសីហនុ ត្បូងឃ្មុំ និងខេត្តឧត្តរមានជ័យ។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ២៥ករណី/១៥ករណី (ធៀបនឹងខែឧសភា មានការកើនឡើង ១០ករណី)ស្មើនឹង៦៦,៦៦% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូង ចំនួន ៣៨នាក់(ស្រី ០៧នាក់) ក្នុងនោះជនសង្ស័យជាជនបរទេសចំនួន ១១នាក់ មាន០៣សញ្ជាតិ (ចិន០៩នាក់ អង់គ្លេស០១នាក់ និងអ៊ីស្រាអែល០១នាក់)។

សង្គ្រោះជនរងគ្រោះ ចំនួន ១៣៣នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ២៤នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ និងអាយុពី១៨ឆ្នាំឡើង ១០៣នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ២១នាក់ និងប្រគល់ឲ្យគ្រួសារ ១១២នាក់) ក្នុងនោះមានចែកជាៈ

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ១៥ករណី លើ០៥ករណី (កើនឡើង ១០ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ២០នាក់ (ស្រី ០៦នាក់) ជនបរទេសសញ្ជាតិអ៊ីស្រាអែល ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១១៩នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១១នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ និងអាយុពី១៨ឆ្នាំឡើង ១០២នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ២១នាក់ និងប្រគល់ឱ្យគ្រួសារ ៩៨នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០២ | ០២ | ០២ | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១ | ១១២ | ១៦ | |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០១ | ០១ | ០១ | |
| -ការទិញពេស្យាចារកុមារ | ០១ | ០៤ | ០១ | អ៊ីស្រាអែល១ |
| *សរុប* | *១៥ ករណី* | *១១៩ នាក់* | *២០នាក់* | *០១ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១០ករណី លើ១០ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៨នាក់(ស្រី ០១នាក់) ជនបរទេស ១០នាក់(ចិន០៩នាក់ អង់គ្លេស០១នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ១៤នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១២នាក់ និងអាយុពី១៨ឆ្នាំឡើង ០២នាក់ (ប្រគល់ឱ្យគ្រួសារ ១៤នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការចាប់ពង្រត់ ការឃុំឃាំងឬបង្ខាំង | ០១ | ០១ | ០៩ | ចិន៩ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០៣ | ០១ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៦ | ០៥ | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៤ | ០៣ | អង់គ្លេស១ |
| *សរុប* | *១០ ករណី* | *១៤ នាក់* | *១៨ នាក់* | *១០ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

ស្នងការដ្ឋាននគរបាលខេត្ត ចំនួន០៤ បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ចំនួន ១៣លើក មនុស្សចំនួន ១៤៥នាក់(ស្រី ៥០នាក់ អនីតិជន ២៧នាក់) ក្នុងនោះមាន៖

- ខេត្តបន្ទាយមានជ័យ ចំនួន ០១លើក មនុស្សចំនួន ២៨នាក់ (ស្រី ១៣នាក់) អនីតិជនចំនួន ០៨នាក់។
- ខេត្តប៉ៃលិន ចំនួន ០២លើក មនុស្សចំនួន ៧១នាក់ (ស្រី ១៥នាក់) អនីតិជនចំនួន ០៧នាក់។
- ខេត្តកោះកុង ចំនួន ០៦លើក មនុស្សចំនួន ២៦នាក់ (ស្រី ០៥នាក់) អនីតិជនចំនួន ០១នាក់។
- ខេត្តស្វាយរៀង ចំនួន ០៤លើក មនុស្សចំនួន ២០នាក់ (ស្រី ១៧នាក់) អនីតិជនចំនួន ១១នាក់។

## ង. ការទទួលសាកសពបញ្ជូនត្រឡប់

ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖ ពលរដ្ឋខ្មែរដែលបានស្លាប់ក្នុងប្រទេសថៃ ហើយត្រូវបានក្រុមគ្រួសារនាំចូលតាមច្រកទ្វារអន្តរជាតិដូង មានចំនួន ០៥នាក់ ស្រី ០២នាក់។

# III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការរៀបបណ្តុះបណ្តាល

ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| ល.រ | សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | ខេត្តកំពត៖ | ០១ | ២០ | ៧ |

| | | | | |
|---|---|---|---|---|
| | លេខាធិការដ្ឋាន សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់សមាជិកលេខាធិការដ្ឋាន ស្តីពីសិទ្ធិរបស់ពលករចំណាកស្រុកធ្វើការលើទូកនេសាទនៅប្រទេសថៃ និងអំពើជួញដូរមនុស្ស។ | | | |
| ២ | ខេត្តកោះកុង៖<br>លេខាធិការដ្ឋាន សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី បើកវគ្គបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល ស្តីពីសិទ្ធិរបស់ពលករចំណាកស្រុកធ្វើការលើទូកនេសាទនៅប្រទេសថៃ និងអំពើជួញដូរមនុស្ស | ០១ | ២៤ | ១០ |
| | សរុប | ០២ វគ្គ | ៤៤ នាក់ | ១៧ នាក់ |

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១ កិច្ចប្រជុំ ជាអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេស

➢ កិច្ចប្រជុំក្នុងប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
  - លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ៖
    - បានដឹកនាំកិច្ចប្រជុំពិភាក្សា ដើម្បីពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនខុសច្បាប់របស់ពលករកម្ពុជា នៅខេត្តបន្ទាយមានជ័យ។
  - លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ៖
    - បានអញ្ជើញដឹកនាំកិច្ចប្រជុំ ស្តីពីការអនុវត្តគោលនយោបាយប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ គ.ជ.ប.ជ ជាមួយតំណាងមកពី អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី វត្តមានសរុបចំនួន ០៦រូប ស្ត្រី០៣រូប នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ។
    - បានអញ្ជើញដឹកនាំកិច្ចប្រជុំស្តីពី សកម្មភាពពិនិត្យផ្ទៀងផ្ទាត់ និងដាក់បញ្ចូលចង្កោមសកម្មភាពតាមលេខរៀងរបស់ក្រុមជំនួយកិច្ចការនីមួយៗ ទៅក្នុងផែនការសកម្មភាពឆ្នាំ ២០២០ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៥៣លើក មានអ្នកចូលរួមសរុប ៦១១នាក់ (ស្រី ២៦៣នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១៩លើក-និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ៣៤លើក។ (ឧបសម្ព័ន្ធ១)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖
- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានធន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែកក្កដា ឆ្នាំ ២០២០

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.........................ខែ...............ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី...........ខែ...........ឆ្នាំ២០២០
**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**
- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**
- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ ( សរុបចំនួន ៥៣លើក ) មនុស្សចំនួន ៦១១នាក់ ( ស្រី ២៦៣នាក់ )

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ( គ.ជ.ប.ជ ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាអធិបតីភាព៖<br>- បានអញ្ជើញជាអធិបតីភាព ក្នុងកិច្ចប្រជុំពិភាក្សាស្ដីពី សេចក្ដីព្រាងខ្លឹមសារអនុស្សរណៈ នៃការយោគយល់គ្នា រវាងមូលនីធិA២១ និងការប្រគល់ទទួលអំណោយជាអង្ករ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានអញ្ជើញជាអធិបតី ក្នុងកិច្ចប្រជុំស្តីពី ផែនការសកម្មភាពនៃកិច្ចសហការ ក្នុងការបង្ការ  ជម្ងឺកូវីដ-១៩ ទៅដល់ពលករចំណាកស្រុកដែលងាយរងគ្រោះ និងក្នុងសហគមន៍ រវាងអង្គការដែលស្ថិតក្រោមអង្គការសហប្រជាជាតិ WHO IOM UNFPA ជាមួយ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។<br>- បានអញ្ជើញចូលរួមជាអធិបតីក្នុងកិច្ចប្រជុំពិភាក្សា អំពីគម្រោងកម្មវិធី ការពារពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍  និងសហគមន៍ ពីហានីភយ័ ឆ្លងជំងឺកូវីដ១៩ ទ្រង់ទ្រាយធំ និងការផ្តល់សេវាចាំបាច់នានានៅមូលដ្ឋាន នៅទីស្តីការក្រសួងមហាផ្ទៃ អគារ T។<br>- បានអញ្ជើញចូលរួមជាអធិបតីបើកកិច្ចប្រជុំស្ដីពី សេចក្ដីប្រកាសរបស់ប្រទេសកាណាដា ទទួលសំណើគម្រោងអាស៊ាន ក្រោមមូលនិធិអាស៊ាន កាណាដាសម្រាប់ផ្តួចផ្តើមថ្នាក់មូលដ្ឋានឆ្នាំ២០២០-២០២១  ស្តីពី  ការរៀបចំឯកសារលើគម្រោងក្នុងមូលនិធិពិសេស  នៃកិច្ចសហប្រតិបត្តិការ(មេគង្គឡានឆាង-NSC-MLC) សម្រាប់ឆ្នាំ២០២១ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានដឹកនាំក្រុមការងាររបស់អគ្គលេខាធិការដ្ឋាន សហការជាមួយអង្គការដៃគូអភិវឌ្ឍ អង្គការ UNFPA បានចុះជួបសំណេះសំណាល ស្តីពីការឆ្លើយតបនឹងវិបត្តិកូវីដ១៩  របស់សហគមន៍ដែលជួបការលំបាកដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស  និងប្រគល់សម្ភារប្រើប្រាស់មួយចំនួនដល់ប្រជាពលរដ្ឋ១០០គ្រួសារ  នៅស្រុកមោងឬស្សី ខេត្តបាត់ដំបង។<br>- បានដឹកនាំក្រុមការងាររបស់អគ្គលេខាធិការដ្ឋាន ក្រុមសមាគមឯកជនចិន បានចុះជួបសំណេះសំណាលស្តីពី ការឆ្លើយតបនឹងវិបត្តិជម្ងឺកូវីដ១៩ របស់សហគមន៍ដែលជួបការលំបាកដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងប្រគល់សម្ភារប្រើប្រាស់មួយចំនួនដល់ប្រជាពលរដ្ឋចំនួន៥០គ្រួសារ នៅក្រុងកំពង់ឆ្នាំង។<br>- បានដឹកនាំក្រុមការងាររបស់អគ្គលេខាធិការដ្ឋាន រួមនឹងអង្គការ UNFPA និង IOM ចុះជួបសំណេះសំណាលស្តីពី ការឆ្លើយតបនឹងវិបត្តិកូវីដ១៩ របស់សហគមន៍ដែលជួបការលំបាកដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងប្រគល់សម្ភារប្រើប្រាស់មួយចំនៈន ដល់ប្រជាពលរដ្ឋចំនួន១០០គ្រួសារ នៅស្រុកកំរៀង ខេត្តបាត់ដំបង។<br>- បានចូលរួមកិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់ទៅលើខ្លឹមសារ សេចក្តីព្រាងសៀវភៅការអប់រំ និងលំនាំ នៃការបង្រៀន ស្តីពីការ បង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស សម្រាប់ថ្នាក់បឋម និងមធ្យមសិក្សា ទាំងរដ្ឋនិងឯកជន នៅសាលប្រជុំ គ.ជ.ប.ជ មានអ្នកចូលរួម១៥នាក់ ស្រី០៣នាក់។ |

- បើកកិច្ចប្រជុំស្តីពី សេចក្តីប្រកាសរបស់ប្រទេសកាណាដា ទទួលសំណើគម្រោងអាស៊ាន ក្រោមមូលនិធិអាស៊ានកាណាដា សម្រាប់ផ្តួចផ្តើមថ្នាក់មូលដ្ឋានឆ្នាំ ២០២០-២០២១ ស្តីពី ការរៀបចំឯកសារលើគម្រោង ក្នុងមូលនិធិពិសេស នៃកិច្ចសហប្រតិបត្តិការ(មេគង្គឡានឆាង-NSC-MLC) សម្រាប់ឆ្នាំ២០២១ នៅសាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ដឹកនាំកិច្ចប្រជុំពិភាក្សាលើសេចក្តីសម្រេចស្តីពីការបង្កើត "មណ្ឌលទទួលពលករចំណាកស្រុក ប្រកដួង" នៅសាលប្រជុំ គជ.ប.ជ. អ្នកចូលរួមចំនួន ១៨នាក់ ស្រី ០៤នាក់ ។

▪ លោកជំទាវវេជ្ជបណ្ឌិត ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួមៈ
- ទទួលអំណោយពីអង្គការ មេត្រីអន្តរជាតិ (AIM) មានជាអង្ករ ២០០គីឡូ និងមីចំនួន ២០កេះ នៅសាលប្រជុំ គ.ជ.ប.ជ។
- ចូលរួមប្រជុំ ពិភាក្សាលើសេចក្តីសម្រេចស្តីពីការបង្កើត"មណ្ឌលទទួលពលករចំណាកស្រុក ប្រកដួង" ក្រោមអធិបតីភាព លោកជំទាវ ជូ **ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។
- អមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អង្គការ UNFPA និង IOM ចូលរួមប្រារព្ធនៅកម្មវិធី សំណេះសំណាលរួមគ្នាមួយស្តីពីការឆ្លើយតប និងវិបត្តិកូវីដ-១៩ របស់សហគមន៍ដែលជួបការលំបាក ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងប្រគល់នូវសម្ភារៈប្រើ ប្រាស់មួយចំនួន ជូនដល់ពលរដ្ឋចំនួន១០០គ្រួសារ នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង ។
- អមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ក្រុមសមាគមឯកជនចិន ដើម្បីចូលរួមកម្មវិធីសំណេះសំណាល ស្តីពីការឆ្លើយតបនឹងវិបត្តិកូវីដ-១៩ របស់សហគមន៍ដែលជួបការលំបាក ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងប្រគល់នូវសម្ភារៈប្រើប្រាស់មួយចំនួន ជូនដល់ ពលរដ្ឋចំនួន៥០គ្រួសារ នៅខេត្តកំពង់ឆ្នាំង។
- ប្រជុំស្តីពីកិច្ចពិភាក្សាការប្រើប្រាស់កញ្ចប់ថវិកាទៅលើគំរោងប្រគល់ជូនរបស់អង្គការសម្ព័នចាប់ដៃ ជូន គ.ជ.ប.ជ នៅពេលខាងមុខ ក្រោមអធិបតីភាពលោក ជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ. នៅសាលប្រជុំ គ.ជ.ប.ជ។
- កិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ ស្តីពីការចាត់ចែងការងារ រវាងស្ថាប័ន និងដៃគូពាក់ព័ន្ធសម្រាប់ការអនុវត្តក្នុងមណ្ឌលទទួលពលករចំណាក នៅស្រុកកំរៀង ខេត្តបាត់ដំបង ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។
- អមដំណើរ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចូលរួមចែកអំណោយដល់ប្រជាពលរដ្ឋ ជនរងគ្រោះ និង ងាយរងគ្រោះរយៈពេលខ្លីដែលទើបត្រឡប់ពីក្រៅប្រទេស និងជួបពិភាក្សាការងារលើគម្រោងសាងសង់មណ្ឌលសំចតទទួលពលករ នៅស្រុកកំរៀង ខេត្ត បាត់ដំបង។

| | |
|---|---|
| | - កិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់ទៅលើខ្លឹមសារសេចក្តីព្រាង សៀវភៅការអប់រំ និងលំនាំនៃការបង្រៀនស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស សម្រាប់ថ្នាក់បឋម និងមធ្យមសិក្សាទាំងរដ្ឋ និងឯកជន ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។<br>- ពិធីប្រគល់ ទទួលសម្ភារៈបរិក្ខារមួយចំនួន ពីតំណាងអង្គការ ASEAN ACT សម្រាប់ជូនជនទេសន្តប្រវេសន៍ដែលជួបការលំបាកតាមបណ្តាខេត្តគោលដៅ ដើម្បីបញ្ចៀសហានិភ័យ នៃអំពើជួញដូរមនុស្សក្នុងស្ថានភាពប្រឈមនឹងជម្ងឺកូវីដ-១៩ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។<br>- កិច្ចប្រជុំពិភាក្សា ពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនខុសច្បាប់របស់ពលករកម្ពុជា ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ.នៅសាលាខេត្តបន្ទាយមានជ័យ។<br>- អមដំណើរលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ តំណាងអង្គការ IOM ជួបសំណេះសំណាសជាមួយពលករទេសន្តរប្រវេសន៍ ស្តីពីការឆ្លើយតបនឹងវិបត្តកូវីដ-១៩ របស់សហគមន៍ដែលជួបការលំបាក ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងបានប្រគល់នូវសម្ភារៈប្រើប្រាស់មួយចំនួនទៅដល់ពលករចំនួន១០០នាក់ នៅស្រុកក្រឡាញ់ ខេត្តសៀមរាប។<br>- ប្រជុំពិភាក្សាស្តីពី សេចក្តីព្រាងខ្លឹមសារអនុស្សរណៈនៃការយោគយល់គ្នារវាងមូលនិធិអេ២១ និងការប្រគល់ទទួលអំណោយឧត្តម្ភជាអង្ករ ដល់គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។<br>- កិច្ចប្រជុំស្តីពី ផែនការសកម្មភាពនៃកិច្ចសហការ ក្នុងការបង្ការជម្ងឺកូវីដ-១៩ ទៅដល់ពលករចំណាកស្រុកដែលងាយរងគ្រោះ ក្នុងសហគន៍ រវាងអង្គការដែលស្ថិតក្រោមអង្គការសហប្រជាជាតិមានដូចជាអង្គការយូនីសេហ្វ IOM WHO UNFPA ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។<br>- កិច្ចប្រជុំពិភាក្សា អំពីគម្រោងកម្មវិធីការពារពលករទេសន្តប្រវេសន៍ ដែលធ្វើមាតុភូមិនិវត្តន៍ និងសហគមន៍ពីហានិភ័យឆ្លងកូវីដ-១៩ ទ្រង់ទ្រាយធំ និងការផ្តល់សេវាចាំបាច់នានានៅមូលដ្ឋាន ក្រោមអធិបតីភាព ឯកឧត្តម **សក់សេដ្ឋា** រដ្ឋលេខាធិការប្រចាំការ និងលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ.នៅទីស្តីការក្រសួងមហាផ្ទៃអាគារ T។<br>- កិច្ចប្រជុំស្តីពី សេចក្តីប្រកាសរបស់ប្រទេសកាណាដាទទួលសំណើរគម្រោងអាស៊ាន ក្រោមមូលនិធិអាស៊ាន-កាណាដា សម្រាប់ផ្តួចផ្តើមថ្នាក់មូលដ្ឋាន ឆ្នាំ២០២០-២០២១ និងការរៀបចំឯកសារលើគម្រោងក្នុងមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (NSC-MLC) សម្រាប់ឆ្នាំ ២០២១ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ ជ.ប.ជ.នៅសាលប្រជុំគ.ជ.ប.ជ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៨ច្បាប់ លិខិតចូល ០៥ច្បាប់។ |

| | |
|---|---|
| | - លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១០ច្បាប់ លិខិតចូល ០៩ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមិថុនា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ខែមិថុនា ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី។<br>- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>- Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ១៨១ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ២១សកម្មភាព។<br>▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌**<br>- ឯកឧត្តម អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការយុត្តិធ៌ម បានអញ្ជើញចូលរួមប្រជុំនៅសាលាបណ្ឌិតសភានគរបាលកម្ពុជា ដើម្បីពិភាក្សារៀបចំសន្ទានុក្រមបច្ចេកសព្ទក្នុងវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់នៃក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍សាស្ត្រាចារ្យ **សេង ផល្លី** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ។<br>- ឯកឧត្តម អគ្គលេខាធិការរង និងលោកប្រធានក្រុមកិច្ចការយុត្តិធម៌ បានចូលរួមប្រជុំពិភាក្សាការងារជាមួយ តំណាងអង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រី និងកុមារ (LSCW) និងវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី (AIT=Asian Institute Technology) ជាស្ត្រី០២រូប សុំកិច្ចសហការធ្វើការសិក្សាស្រាវជ្រាវស្តីពី «ប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ គោលនយោបាយ និងកិច្ចព្រមព្រៀងទ្វេភាគីរវាងកម្ពុជា ថៃ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស «នៅសាលប្រជុំគ.ជ.ប.ជ។<br>- ឯកឧត្តម អគ្គលេខាធិការរង លោកប្រធានក្រុមកិច្ចការយុត្តិធម៌ លោកទីប្រឹក្សា គ.ជ.ប.ជ ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ជំនួយកិច្ចការបង្ការទប់ស្កាត់ បានចូលរួមពិនិត្យ កែសម្រួលសេចក្តីព្រាង MOU របស់តំណាងអង្គការ « មូលនិធី អេ ២១ » ចំនួនពីររូប ដែលបានស្នើសុំកិច្ចសហការជាមួយ គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវជួប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និង លោកជំទាវ អគ្គលេខាធិការ នៅសាលប្រជុំគ.ជ.ប.ជ។<br>- បានចូលរួមកិច្ចប្រជុំជាមួយ ប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ជំនួយកិច្ចការការពារ ជនរងគ្រោះ និងជំនួយកិច្ចការអនុវត្តច្បាប់ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងដាក់បញ្ចូលចង្កោមសកម្មភាពរបស់ក្រុមជំនួយកិច្ចការនីមួយៗ តាមលេខរៀងដូចដើមទៅក្នុងផែនការសកម្មភាពឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន នៅសាលប្រជុំគ.ជ.ប.ជ។ |

▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

- លោកជំទាវ អគ្គលេខាធិការរង បានអញ្ជើញចូលរួម ពិភាក្សាពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនដោយខុសច្បាប់របស់ពលករកម្ពុជា របស់ខេត្តទាំងបួន បន្ទាយមានជ័យ បាត់ដំបង សៀមរាប និងឧត្តរមានជ័យ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលាខេត្តបន្ទាយមានជ័យ។
- លោកជំទាវ អគ្គលេខាធិការរង បានអមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ តំណាងអង្គការ IOM ជួបសំណេះសំណាលជាមួយពលករទេសន្តប្រវេសន៍ស្តីពីការឆ្លើយតបនឹងវិបត្តិកូវីដ១៩ របស់សហគមន៍ និងប្រគល់សម្ភារប្រើប្រាស់មួយចំនួន ចំនួន១០០គ្រួសារ នៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប។
- លោកជំទាវ អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី "គម្រោងកម្មវិធីការពារពលករទេសន្តប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ និងសហគមន៍ពីហានីភ័យឆ្លងជំងឺកូវីដ១៩ទ្រង់ទ្រាយធំ និងការផ្តល់សេវាចាំបាច់នានានៅមូលដ្ឋាន" ក្រោមអធិបតីភាព ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការ និងលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃអគារ S។
- បានចូលរួមកិច្ចប្រជុំជាមួយ ប្រធានក្រុមជំនួយកិច្ចការទេសន្តប្រវេសន៍ ជំនួយកិច្ចការការពារ ជនរងគ្រោះ និងជំនួយកិច្ចការអនុវត្តច្បាប់ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងដាក់បញ្ចូលចង្កោមសកម្មភាពរបស់ក្រុមជំនួយកិច្ចការនីមួយៗ តាមលេខរៀងដូចដើមទៅក្នុងផែនការសកម្មភាពឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។
- លោកជំទាវ អគ្គលេខាធិការរង បានចូលរួមក្នុងកិច្ចពិភាក្សាស្តីពី "ការពិគ្រោះយោបល់ពិភាក្សា លើការចាត់ចែងការងាររវាងស្ថាប័ន និងដៃគូពាក់ព័ន្ធ សម្រាប់ការអនុវត្តក្នុងមណ្ឌលទទួលពលករចំណាកស្រុកនៅស្រុកកំរៀងខេត្តបាត់ដំបង" ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។
- លោកស្រី អនុប្រធានក្រុម បានចូលរួមជាមួយ ថ្នាក់ដឹកនាំក្រុមជំនួយកិច្ចការការពារជនរងគ្រោះ២រូប ផ្តល់កិច្ចសម្ភាសន៍តាមរយៈប្រព័ន្ធអ៊ីនធើណិត (SKYPE Video Conference) ក្នុងការស្រង់ទិន្នន័យសម្រាប់ការស្រាវជ្រាវ លើការអនុវត្ត "គម្រោងផ្តល់វគ្គបណ្តុះបណ្តាលអំពីការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត" របស់អង្គការអន្តរជាតិសម្រាប់ទេសន្តរប្រវេសន៍ (IOM)។
- លោកប្រធានក្រុមការងារ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពី "សេចក្តីព្រាងខ្លឹមសារអនុស្សរណៈយោគយល់គ្នារវាងមូលនីធិA២១ និងការប្រគល់ទទួលអំណោយជាអង្ករ" ជូនគ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់៖**

- ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានដឹកនាំក្រុមការងារ ចូលរួមប្រជុំរៀបចំគម្រោងសិក្ខាសាលា ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ សម្រាប់ការចុះបណ្តុះបណ្តាលសាកល្បងលើសៀវភៅការអប់រំ និងលំនាំនៃការបង្រៀន ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ជូនដល់គ្រូឧទ្ទេសភូមិភាគ និងគរុសិស្សឆ្នាំទី២ ខេត្តកំពង់ចាម នៅសាលប្រជុំក្រសួងអប់រំ យុវជន និងកីឡា។

- ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានដឹកនាំក្រុមការងារចូលរួមសហការជាមួយក្រសួងអប់រំយុវជននិងកីឡា ចុះផ្សព្វផ្សាយ និងបណ្តុះបណ្តាលសាកល្បងសៀវភៅអប់រំ និងលំនាំនៃការបង្រៀន ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដើម្បីប្រមូលធាតុចូលបន្ថែម សម្រាប់កែលម្អការតាក់តែងសៀវភៅ និងផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងជម្ងឺកូវីដ១៩ ជូនដល់គ្រូឧទ្ទេស និងគរុសិស្ស នៅខេត្តកំពង់ចាម។
- ប្រធានក្រុម និងមន្ត្រី០១រូប បានទៅចូលរួមប្រជុំពិភាក្សាកែសម្រួលអក្ខរាវិរុទ្ធ ខ្លឹមសារអត្ថបទ និងខ្លឹមសាររូបភាពសៀវភៅអប់រំ និងលំនាំនៃការបង្រៀនស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ថ្នាក់មធ្យមសិក្សា នៅសាលប្រជុំនៃក្រសួងអប់រំ យុវជន និងកីឡា។

- **ក្រុមជំនួយកិច្ចការពារជនរងគ្រោះ៖**

- លោកឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង បានចូលរួមកិច្ចប្រជុំ ស្តីពីការអនុវត្ត គោលនយោបាយប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ ជូ **ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។
- លោកប្រធានក្រុម សហការជាមួយ UNFPA IOM និងភ្នាក់ងារដទៃទៀត បានចុះធ្វើការវាយតម្លៃអំពីផលប៉ះពាល់សង្គម និងសុខភាពដោយ ជំងឺកូវីដ ១៩ លើពលករទេសន្តប្រវេសន៍ ដែលបានវិលត្រឡប់មកវិញ នៅខេត្តចំនួន៣ (សៀមរាប បាត់ដំបង បន្ទាយមានជ័យ)។
- លោកប្រធានក្រុមការងារ បានចូលរួមប្រជុំបូកសរុបរបាយការណ៍ ឆមាសទី ០១ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោមអធិបតីភាព ឯកឧត្តម ញឹក វណ្ណ៉ា រដ្ឋលេខាធិការ ក្រសួងសង្គកិច្ច នៅសាលប្រជុំទីស្តីការក្រសួងសង្គមកិច្ច។
- លោកប្រធាន និងអនុប្រធានក្រុមការងារ បានចូលរួម កិច្ចប្រជុំពិភាក្សាស្តីពី ការពង្រឹង វិធានការទប់ស្កាត់ និងគ្រប់គ្រងពលករឆ្លងដែន ដោយខុសច្បាប់ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលាខេត្តបន្ទាយមានជ័យ។
- លោកឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង និងលោកប្រធានក្រុមការងារបានចុះទទួលជនរងគ្រោះ នៅច្រកទ្វារអន្តរជាតិបាវិត ក្រុងបាវិត ខេត្តស្វាយរៀងចំនួន ០៣នាក់ ដែលអាជ្ញាធរ វៀតណាមឃាត់ខ្លួនបាន ដោយបានលួចរត់ឆ្លងមកពីប្រទេសចិន ដោយបានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនិតិសម្បទា និងអង្គការចាប់ដៃ។

- **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់៖**

- ឯកឧត្តម អគ្គលេខាធិការរង បានចូលរួមកិច្ចប្រជុំប្រមូលព័ត៌មានអំពីម្តាយ និងកូនស្រីដែលរងគ្រោះនៅប្រទេសចិន ហើយត្រូវបានជួយសង្គ្រោះ ត្រឡប់មកប្រទេសកម្ពុជាវិញតាមច្រកប្រទេសវៀតណាម នៅសាលប្រជុំគ.ជ.ប.ជ។
- ឯកឧត្តម អគ្គលេខាធិការរង បានអមដំណើរលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ចូលរួមកម្មវិធីសំណេះសំណាល និងចែកអំណោយជូនប្រជាពលរដ្ឋដែលទើបវិលត្រឡប់មកពីក្រៅប្រទេស នៅស្រុកកំរៀង ខេត្តបាត់ដំបង។
- ឯកឧត្តម អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីការពង្រឹងវិធានការទប់ស្កាត់និងគ្រប់គ្រងការឆ្លងដែនដោយខុសច្បាប់ របស់ពលករកម្ពុជា ក្រោមអធិបតីភាពលោកជំទាវជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ. នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ។

Puthabi

| | |
|---|---|
| | - ឯកឧត្តម អគ្គលេខាធិការរង បានអមដំណើរលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គជ.ប.ជ. លោកជំទាវ អគ្គលេខាធិការ ជួបសំណេះសំណាលជាមួយពលករទេសន្តប្រវេសន៍ចំនួន១០០នាក់ ស្តីពីការឆ្លើយតបនឹងវិបត្តិកូវីដ ១៩ របស់សហគមន៍ដែលជួបការលំបាកដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងប្រគល់សម្ភារ ប្រើប្រាស់មួយចំនួន ដែលទទួលបានការឧបត្ថម្ភគាំទ្រពីអង្គការដៃគូមាន:UNFPA និងIOM ដល់ប្រជាពលរដ្ឋដែលទើបវិលត្រឡប់ពីក្រៅប្រទេស នៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៣៤លើក អ្នកចូលរួមសរុបចំនួន ៥៧៨នាក់ (ស្រី ២៥៦នាក់)** | |
| **ខេត្តកណ្តាល** | - គ.ខ.ប.ជ ដឹកនាំដោយលោកជំទាវ ហ៊ុន កុសនី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ និងទិសដៅបន្តឆ្នាំ ២០២០ ចំនួន០១លើក អ្នកចូលរួមចំនួន ៦៧នាក់ ស្រី៤០នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន ០៨លើក អ្នកចូលរួមចំនួន ១៩៥នាក់ ស្រី១២៧នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានប្រជុំពង្រឹងសមត្ថភាពក្រុមការងារ ចំនួន ១៧លើក អ្នកចូលរួម ១៥៧នាក់ ស្រី ០៨នាក់។ |
| **ខេត្តស្វាយរៀង** | - លេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំឆ្លងរបាយណ៍ប្រចាំឆមាសទី១ និងទិសដៅបន្ត សហការជាមួយអង្គការឆោលហ្វាន់ អ្នកចូលរួម៥៧នាក់ ស្រី២៨នាក់។ |
| **ខេត្តសៀមរាប** | - គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំឆមាសទី១ ឆ្នាំ២០២០ ចំនួន ០១លើក អ្នកចូលរួម ៦០នាក់ ស្រី៣៨នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ បានប្រជុំពង្រឹងសមត្ថភាព ដល់សមាជិកលេខាការដ្ឋានថ្នាក់ខេត្ត ក្រុង ស្រុក ស្តីពីការលើកកម្ពស់ការយល់ដឹងអំពី កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត និងរបៀបរាយការណ៍ប្រកបដោយសុវត្ថិភាព ចំនួន ០១លើក មានអ្នកចូលរួម ២៣នាក់ ស្រី១៧នាក់។ |
| **ខេត្តបាត់ដំបង** | - ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត បានចូលរួមប្រជុំពិភាក្សាដើម្បីពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនខុសច្បាប់របស់ពលករកម្ពុជា ចំនួន០១លើក នៅសាលាខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- បានចូលរួមអមដំណើរលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចុះសំណេះសំណាលជាមួយពលករ និងពិនិត្យទីតាំងសំចតរបស់ពលករកម្ពុជានៅស្រុកកំរៀង។ |
| **ខេត្តកោះកុង** | - ស្នងការដ្ឋាននគរបាលខេត្តបានរៀបចំកម្មវិធីសំណេះសំណាលពង្រឹងសមត្ថភាពយេនឌ័រ និងផ្សព្វផ្សាយក្រមប្រតិបត្តិយេនឌ័រ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមជាមន្ត្រីនគរបាលនារីចំនួន២២នាក់។ |
| **ខេត្តឧត្តរមានជ័យ** | - បានប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារ ចំនួន ០១លើក មានអ្នកចូលរួម ១៩នាក់ ស្រី ១៦នាក់។ |
| **ខេត្តកំពង់ធំ** | -ក្រុមការងារលេខាធិការដ្ឋាន ខេត្តបានចូលរួមកិច្ចប្រជុំប្រចាំខែឧសភា ឆ្នាំ២០២០ របស់គណៈកម្មាការពិគ្រោះយោបល់ស្ត្រី និងកុមារ នៅសាលាខេត្ត ចំនួន០១លើក។ |